**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរខណ្ឌ នៃខេត្តប៉ៃលិនទៅជាក្រុង និង ជាស្រុក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្តូរក្រុងប៉ៃលិនទៅជាខេត្តប៉ៃលិន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១ .—**

ត្រូវបានប្តូរខណ្ឌ នៃខេត្តប៉ៃលិន ទៅជាក្រុង និង ជាស្រុក ដូចខាងក្រោម :

- ខណ្ឌប៉ៃលិន ទៅជា ក្រុងប៉ៃលិន
- ខណ្ឌសាលាក្រៅ ទៅជា ស្រុកសាលាក្រៅ។

មាត្រា ២ .—

ក្រុងប៉ៃលិន មានសង្កាត់ ០៤ គឺ :

- សង្កាត់ប៉ៃលិន
- សង្កាត់បរយ៉ាខា
- សង្កាត់ទួលល្វា
- សង្កាត់អូរតាវ៉ៅ ។

**មាត្រា ៣ .—**

ត្រូវបានប្តូរសង្កាត់ នៃស្រុកសាលាក្រៅ ទៅជាឃុំ ដូចខាងក្រោម :

- សង្កាត់ស្ទឹងកាច់ ទៅជា ឃុំស្ទឹងកាច់
- សង្កាត់សាលាក្រៅ ទៅជា ឃុំសាលាក្រៅ
- សង្កាត់អូរអណ្តូង ទៅជា ឃុំអូរអណ្តូង
- សង្កាត់ស្ទឹងត្រង់ ទៅជា ឃុំស្ទឹងត្រង់ ។

**មាត្រា ៤ .—**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុង និង ស្រុក នៃខេត្តប៉ៃលិន ត្រូវអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តប៉ៃលិន អភិបាលក្រុង អភិបាលស្រុក និង ក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*( ដើម្បីជូនជ្រាប )*

- *ដូចមាត្រា ៦*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*